# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកសៀមរាប ទៅជាក្រុងសៀមរាប នៃខេត្តសៀមរាប

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សម្រេច

មាត្រា ១.-

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងស្រុកសៀមរាប ស្រុកពួក និង ស្រុកប្រាសាទបាគង នៃខេត្តសៀមរាប ដោយកាត់យកឃុំទឹកវិល ឃុំក្របីរៀល ពីស្រុកពួក និង ឃុំអំពិលពីស្រុកប្រាសាទបាគង បញ្ចូលទៅក្នុងស្រុកសៀមរាប នៃខេត្តសៀមរាប ។

www.pheakdeylaw.com

មាត្រា ២.-

ត្រូវបានប្តូរស្រុកសៀមរាប ទៅជា ក្រុងសៀមរាប នៃខេត្តសៀមរាប ។

ព្រំប្រទល់រដ្ឋបាលនៃ ក្រុងសៀមរាប ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ៣.-

ត្រូវបានប្តូរឃុំទាំងដប់បីនៃ ក្រុងសៀមរាប ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- ឃុំស្រង៉ែ | ទៅជា | សង្កាត់ស្រង៉ែ |
| ២- ឃុំស្វាយដង្គុំ | ទៅជា | សង្កាត់ស្វាយដង្គុំ |
| ៣- ឃុំគោកចក | ទៅជា | សង្កាត់គោកចក |
| ៤- ឃុំសាលាកំរើក | ទៅជា | សង្កាត់សាលាកំរើក |
| ៥- ឃុំនគរធំ | ទៅជា | សង្កាត់នគរធំ |
| ៦- ឃុំជ្រាវ | ទៅជា | សង្កាត់ជ្រាវ |
| ៧- ឃុំចុងឃ្នៀស | ទៅជា | សង្កាត់ចុងឃ្នៀស |
| ៨- ឃុំសំបួរ | ទៅជា | សង្កាត់សំបួរ |
| ៩- ឃុំសៀមរាប | ទៅជា | សង្កាត់សៀមរាប |
| ១០- ឃុំស្លក្រាម | ទៅជា | សង្កាត់ស្លក្រាម |
| ១១- ឃុំទឹកវិល | ទៅជា | សង្កាត់ទឹកវិល |
| ១២- ឃុំក្របីរៀល | ទៅជា | សង្កាត់ក្របីរៀល |
| ១៣- ឃុំអំពិល | ទៅជា | សង្កាត់អំពិល |

មាត្រា ៤.-

ត្រូវផ្ទេរទីតាំងសាលាស្រុកសៀមរាប ដែលស្ថិតនៅក្នុងសង្កាត់ស្រង៉ែ ទៅជាសាលា ក្រុងសៀមរាប ។

មាត្រា ៥.-

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុងសៀមរាប ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

មាត្រា ៦.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តសៀមរាប អភិបាលក្រុងសៀមរាប អភិបាលស្រុកពួក

www.pheakdeylaw.com

អភិបាលស្រុកប្រាសាទបាគង និងក្រុមប្រឹក្សាឃុំ សង្កាត់ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

(ដើម្បីជូនជ្រាប)

- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com

# ផែនទី រដ្ឋបាល ក្រុងសៀមរាប




ពេជ្រ_សុខារ៉ៃយ

ទូច_សំអាត

សៅ ម៉ុនចាយ

ស៊ូ_ភិរិន្ទ

ស ខេង